ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០០៣........សហវ.....

# សារាចរ
# ស្តីពី
# នីតិវិធីអនុវត្តការងារដោះស្រាយផលប៉ះពាល់
# ដោយសារគម្រោងអភិវឌ្ឍន៍នានា

ការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍នានា ត្រូវបានកំណត់ជាគោលការណ៍ ដោយរាជរដ្ឋាភិបាល តាមរយៈចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១០ លើលិខិតលេខ ៧១៨៨ សហវ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងផ្អែកតាមគោលនយោបាយដោះស្រាយផលប៉ះពាល់របស់ដៃគូអភិវឌ្ឍដែលជាអ្នកផ្តល់ហិរញ្ញប្បទាន និងអនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដែលមានជាអាទិ៍ ច្បាប់ស្តីពីអស្សាមិករណ៍ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០, ច្បាប់ភូមិបាល ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១, អនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា។

ដើម្បីធានាការអនុវត្តការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍នីមួយៗ ប្រកបដោយប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ, ជៀសវាងបាននូវផលប៉ះពាល់ផ្នែកសតិអារម្មណ៍បន្ថែមលើផលប៉ះពាល់ផ្នែកទ្រព្យសម្បត្តិ ដល់ប្រជាពលរដ្ឋរងផលប៉ះពាល់, ជៀសវាងបាននូវការរាំងស្ទះដល់ការងារវិស្វកម្មសម្រាប់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលបម្រើឱ្យផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ, និងដើម្បីទទួលបានការគាំទ្រពេញលេញពីប្រជាពលរដ្ឋទូទៅ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចខាងក្រោម÷

## ក. ដំណាក់កាលសិក្សាពីសមិទ្ធិលទ្ធភាពនៃគម្រោងអភិវឌ្ឍន៍

១-ជាគោលការណ៍ ការងារវិស្វកម្មលើគម្រោងអភិវឌ្ឍន៍ អាចចាប់ផ្តើមដំណើរការបាន លុះត្រាតែការងារដោះស្រាយផលប៉ះពាល់ ត្រូវបានបញ្ចប់ជាមុនសិន។ ក្នុងន័យនេះ ការអនុវត្តការងារវិស្វកម្មគម្រោងអាចត្រូវ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

បានរាំងស្ទះ ប្រសិនបើទំហំនៃផលប៉ះពាល់លើទ្រព្យសម្បត្តិផ្សេងៗរបស់ប្រជាពលរដ្ឋ មិនត្រូវបានសិក្សាឱ្យបានច្បាស់លាស់តាំងពីដំណាក់កាលសិក្សាពីសមិទ្ធិលទ្ធភាពរបស់គម្រោងនោះទេ។

ហេតុដូច្នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមស្នើសុំដល់គ្រប់ក្រសួង-ស្ថាប័នអនុវត្តគម្រោងស្តារ ពង្រីក និងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ផ្តល់កិច្ចសហការជាមួយនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យលទ្ធភាពបញ្ចៀសផលប៉ះពាល់ ឬធ្វើអប្បបរមានីយកម្មផលប៉ះពាល់ ដោយសារគម្រោងអភិវឌ្ឍន៍ តាំងពីដំណាក់កាលសិក្សាពីសមិទ្ធិលទ្ធភាពនៃគម្រោងនីមួយៗ។

២- ដោយឡែក ការរៀបចំផែនការបឋមនៃការងារដោះស្រាយផលប៉ះពាល់ ត្រូវធ្វើឡើងដោយក្រសួង-ស្ថាប័នអនុវត្តគម្រោង ដោយមានជំនួយពីទីប្រឹក្សាបច្ចេកទេសរបស់គម្រោង ឬដោយទីប្រឹក្សាបច្ចេកទេសរបស់គម្រោងផ្ទាល់។ ផែនការបឋមនេះ ត្រូវដាក់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដើម្បីពិនិត្យនិងអនុម័ត មុននឹងបញ្ជូនទៅដៃគូអភិវឌ្ឍផ្តល់ហិរញ្ញប្បទាន ដើម្បីអនុវត្តបន្តតាមនីតិវិធីជាធរមាន។

**ខ. ដំណាក់កាលអនុវត្តផែនការដោះស្រាយផលប៉ះពាល់**

១-ក្រោយពីទទួលបានសំណើសុំដោះស្រាយផលប៉ះពាល់ ពីក្រសួង-ស្ថាប័នអនុវត្តគម្រោង នាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ត្រូវរៀបចំស្នើសុំបង្កើតគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ សម្រាប់គម្រោងនីមួយៗ ហើយគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ ដែលត្រូវបានបង្កើតនេះ ត្រូវរៀបចំស្នើសុំអភិបាលរាជធានី-ខេត្តពាក់ព័ន្ធ ធ្វើការបង្កើតអនុគណៈកម្មការដោះស្រាយផលប៉ះពាល់ ដើម្បីត្រៀមសហការអនុវត្តការងារ។

២-នៅមុនពេលចាប់ផ្តើមអនុវត្តការងារដោះស្រាយផលប៉ះពាល់ ដើម្បីធានាឱ្យការអនុវត្តការងារដោះស្រាយផលប៉ះពាល់ ប្រព្រឹត្តទៅដោយភាពរលូន និងមានផលប៉ះពាល់ជាអប្បបរមា តំណាងក្រសួង-ស្ថាប័នអនុវត្តគម្រោង ដែលជាសមាជិកនៃគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ ត្រូវរៀបចំលិខិតស្នើសុំជាផ្លូវការរបស់សាមីក្រសួង-ស្ថាប័នអនុវត្តគម្រោង ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ រួមមានជាអាទិ៍ គំនូសប្លង់បច្ចេកទេសលម្អិត និងការសិក្សាអំពីជម្រើសដោះស្រាយផលប៉ះពាល់យ៉ាងតិចចំនួនពីរ ដើម្បីគណៈ-កម្មការអន្តរក្រសួងអាចមានលទ្ធភាពជ្រើសរើសយកជម្រើសណាមួយ ដែលអាចកាត់បន្ថយផលប៉ះពាល់របស់គម្រោងឱ្យនៅតិចបំផុត។

៣-ក្រោយពីទទួលបានគំនូសប្លង់បច្ចេកទេសលម្អិត និងមុនពេលចាប់ផ្តើមអនុវត្តការងារដោះស្រាយផលប៉ះពាល់ គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ ត្រូវស្នើសុំនិងទទួលបានការអនុម័តជា

គោលការណ៍ ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើសំណើសុំបុរេប្រទានថវិកាសម្រាប់ចំណាយលើដំណើរការរបស់ក្រុមការងារ និងត្រូវមានថវិកាក្នុងគណនីរបស់គម្រោងជាមុនសិន។

៤-តាមលក្ខណៈបច្ចេកទេស ការអង្កេតវាស់វែងលម្អិតលើផលប៉ះពាល់ នឹងត្រូវបានធ្វើឡើងផ្អែកតាមសំណើរបស់ក្រសួង-ស្ថាប័នអនុវត្តគម្រោង និងស្របតាមគំនូសប្លង់បច្ចេកទេសលម្អិតរបស់គម្រោងតែប៉ុណ្ណោះ។ ហេតុដូចនេះ គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ នឹងមិនអនុញ្ញាតឱ្យក្រុមការងារចុះធ្វើការអង្កេតវាស់វែងលម្អិតឡើយ ប្រសិនបើពុំទាន់មានគំនូសប្លង់បច្ចេកទេសលម្អិតដែលត្រូវបានអនុម័តដោយក្រសួង-ស្ថាប័នអនុវត្តគម្រោងទេ។

គោលការណ៍នេះ ក៏នឹងត្រូវអនុវត្តផងដែរចំពោះរាល់ការកែប្រែគំនូសប្លង់បច្ចេកទេសរបស់គម្រោងអភិវឌ្ឍន៍នីមួយៗ។

៥-រាល់ព្យសនកម្មពីការឈូសឆាយទីតាំងដែលទទួលរងនូវផលប៉ះពាល់ ដោយសារគម្រោងអភិវឌ្ឍន៍ដោយក្រុមហ៊ុនសាងសង់ ដោយមិនគោរពតាមគំនូសប្លង់បច្ចេកទេសលម្អិត និង/ឬ ដោយមិនបានគោរពតាមនីតិវិធី និងគោលការណ៍ណែនាំក្នុងសារាចរនេះ ត្រូវស្ថិតក្រោមការទទួលខុសត្រូវ និងជាបន្ទុកផ្ទាល់របស់ក្រុមហ៊ុនសាងសង់ពាក់ព័ន្ធ។

អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបន្តសហការជាមួយក្រសួង-ស្ថាប័នអនុវត្តគម្រោង ដើម្បីរៀបចំបញ្ចូលខ្លឹមសារនៃចំណុច ខ៥ នេះ ទៅក្នុងកិច្ចសន្យាសាងសង់។

៦-មុនពេលដែលក្រុមការងារចាប់ផ្តើមចុះធ្វើការពិនិត្យនិងវាយតម្លៃលម្អិតលើផលប៉ះពាល់ គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ ត្រូវរៀបចំវេទិកាមួយ ដែលត្រូវមានការចូលរួមពីអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ដែលមានការពាក់ព័ន្ធ ជំនួសឱ្យកិច្ចប្រជុំធម្មតាជាមួយនឹងអនុគណៈកម្មការដោះស្រាយផលប៉ះពាល់ ។ វេទិកានេះមានគោលបំណងពន្យល់ផ្សព្វផ្សាយព័ត៌មានមូលដ្ឋានអំពីគម្រោង គោលនយោបាយដោះស្រាយផលប៉ះពាល់ គំនូសប្លង់បច្ចេកទេសរបស់គម្រោង និងពង្រឹងសមត្ថភាពរបស់មន្ត្រី នៃរដ្ឋបាលថ្នាក់ក្រោមជាតិ លើគោលនយោបាយ និងនីតិវិធីនៃការងារដោះស្រាយផលប៉ះពាល់។

៧-គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ ត្រូវណែនាំដល់ក្រុមការងារឱ្យពន្យល់ពីមូលដ្ឋានច្បាប់ និងសម្របសម្រួលដោយសន្តិវិធីជាមួយប្រជាពលរដ្ឋ ឱ្យធ្វើការរុះរើដោយខ្លួនឯង នូវសំណង់ស្រាលៗ និងរោងតូចតាចដែលអាចរំកិលបាន ដូចជាតូបលក់ដូរតូចតាចធុនស្រាល ក្រោលគោ រោងចំបើង ឬទ្រុងមាន់-ទា ជាដើម ដែលបានសង់នៅលើដីចំណីផ្លូវ ដោយមិនធ្វើការដោះស្រាយជាប្រាក់ឧបត្ថម្ភគោលនយោបាយជូនពួកគាត់នោះទេ។ ⁄

៨- ក្រោយពេលបញ្ចប់ការអង្កេតវាស់វែងលម្អិត និងបន្ទាប់ពីផែនការដោះស្រាយផលប៉ះពាល់ត្រូវបានធ្វើបច្ចុប្បន្នភាពរួចហើយ គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ ត្រូវស្នើសុំការអនុម័តជាគោលការណ៍ពីរាជរដ្ឋាភិបាល នូវកញ្ចប់ថវិកាសម្រាប់អនុវត្តផែនការដោះស្រាយផលប៉ះពាល់នេះជាមុនសិន។

៩-សំណើសុំដកថវិកាសម្រាប់ទូទាត់ជាប្រាក់សំណង ឬប្រាក់ឧបត្ថម្ភផ្សេងៗដល់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ត្រូវធ្វើឡើងដោយអនុលោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។ គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ ត្រូវដោះស្រាយដោយផ្អែកតាមផែនការការងារសាងសង់ដែលត្រូវបានស្នើឡើងដោយក្រសួង-ស្ថាប័នអនុវត្តគម្រោង។ ក្រុមការងារនៃគណៈកម្មការអន្តរក្រសួង ត្រូវសហការជាមួយក្រុមការងារនៃអនុគណៈកម្មការដោះស្រាយផលប៉ះពាល់ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការបើកផ្តល់ប្រាក់សំណង ឬប្រាក់ឧបត្ថម្ភផ្សេងៗជូនប្រជាពលរដ្ឋរងផលប៉ះពាល់។

១០-នៅគ្រប់ដំណាក់កាល នៃការអនុវត្តផែនការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដូចជា ការអង្កេតវាស់វែងលម្អិត, ការចរចាចុះកិច្ចសន្យា និងការបើកផ្តល់ប្រាក់សំណង ឬ ប្រាក់ឧបត្ថម្ភគោលនយោបាយ គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ ត្រូវរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ និងកិច្ចប្រជុំផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយ ដល់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង។

**គ. ដំណាក់កាលក្រោយការអនុវត្តផែនការដោះស្រាយផលប៉ះពាល់**

១-ក្រោយពេលបញ្ចប់ការងារដោះស្រាយផលប៉ះពាល់ គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ ត្រូវធ្វើលិខិតប្រគល់-ទទួលទីតាំង និងការគ្រប់គ្រងទីតាំងដែលបានដោះស្រាយ ឬធ្វើលទ្ធកម្មរួច ទៅអាជ្ញាធរកាន់កាប់ដីរដ្ឋ និងជូនដំណឹងទៅអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្រសួង-ស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវដំណើរការចុះបញ្ជីទីតាំងដែលបានដោះស្រាយរួច ចូលក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ តាមនីតិវិធីជាធរមាន។

២- អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបន្តសហការជាមួយក្រសួង-ស្ថាប័នអនុវត្តគម្រោង ដើម្បីរៀបចំបញ្ចូលក្នុងកិច្ចសន្យាសាងសង់នូវ ខសន្យា ដែលតម្រូវឱ្យក្រុមហ៊ុនសាងសង់ ត្រូវធ្វើការសម្អាតទីតាំងការដ្ឋានឱ្យបានស្អាត ជៀសវាងផលប៉ះពាល់បន្ថែមដល់ទ្រព្យសម្បត្តិ និងសកម្មភាពសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់។

៣- អនុគណៈកម្មការដោះស្រាយផលប៉ះពាល់ ត្រូវចាត់វិធានការម៉ឺងម៉ាត់ ដើម្បីធ្វើការរុះរើសំណង់និងទ្រព្យសម្បត្តិផ្សេងៗ ដែលបានដោះស្រាយជាប្រាក់សំណង ឬប្រាក់ឧបត្ថម្ភគោលនយោបាយរួចរាល់ហើយ។

៤- ក្រោយបញ្ចប់គម្រោង អនុគណៈកម្មការដោះស្រាយផលប៉ះពាល់ ត្រូវពង្រឹងការគ្រប់គ្រងនិងទប់ស្កាត់រាល់ការទន្ទ្រានកាន់កាប់សារជាថ្មី លើដីរដ្ឋដែលបានដោះស្រាយរួច។ គណៈកម្មការអន្តរក្រសួងដោះ

ស្រាយផលប៉ះពាល់ មិនត្រូវធ្វើការដោះស្រាយជាសំណង ឬប្រាក់ឧបត្ថម្ភគោលនយោបាយចំពោះសំណង់ និងទ្រព្យសម្បត្តិផ្សេងៗដែលបានសាងសង់ ឬរៀបចំឡើងនៅលើទីតាំងដែលធ្លាប់បានដោះស្រាយរួចហើយនោះឡើយ ប្រសិនបើមានតម្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍបន្ថែមទៀតនាពេលអនាគត។

ទទួលបានសារាចរនេះ នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ និងអនុគណៈកម្មការដោះស្រាយផលប៉ះពាល់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុវិញ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់អគ្គនាយកដ្ឋាន នៃ កសហវ
- សាលារាជធានី ខេត្ត
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ